គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារពិសេសតាមការចាំបាច់ ក្នុងការបំពេញតួនាទី និងភារកិច្ចដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការ។

ប្រការ៥ .-

គណៈកម្មការនេះ មានទីតាំងនៅអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងមានសិទ្ធិប្រើត្រារបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដើម្បីដំណើរការការងាររបស់ខ្លួន។

ប្រការ៦ .-

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀតដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងជួយឧបត្ថម្ភដល់ដំណើរការរៀបចំកិច្ចប្រជុំកំពូលសៀមរាប-អង្គរ។

ប្រការ៧ .—

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៨ .—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៨៥ សសរ

សេចក្តីសម្រេច

ស្តីពី

ការចាត់តាំង បំពេញបន្ថែម និងកែសម្រួលសមាសភាព

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ២២១ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមសំណើរបស់ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម

សម្រេច

ប្រការ១ .-

ត្រូវបានបំពេញបន្ថែមសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ដូចខាងក្រោម៖

១- ឯកឧត្តម **ម៉ែន ទិបុល**	រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី	អនុប្រធាន
២- ឯកឧត្តម **ពៅ សាលីដេត**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៣- ឯកឧត្តម **លូ គឹមឈន់**	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តខេត្តព្រះសីហនុ	អនុប្រធាន។

ប្រការ២ .-

ត្រូវបានកែសម្រួលសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ពីសមាជិកមកជាអនុប្រធាន ដូចខាងក្រោម៖

១- ឯកឧត្តម **ប្រាក់ សំអឿន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

២- ឧត្តមសេនីយ៍ឯក **ឡោ សុឡេខ** អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ

៣- ឧត្តមសេនីយ៍ឯក **លន់ សុផាត** អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ។

ប្រការ៣ .-

ត្រូវបានចាត់តាំងឯកឧត្តម **ពេជ្រ សម្បត្តិ** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ជំនួស ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ ទិជិត្ត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម។

ប្រការ៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម រដ្ឋបាលខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២៣

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៨៦ សសរ

សេចក្តីសម្រេច

ស្តីពី

ការបំពេញបន្ថែមសមាសភាព ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្តីសម្រេចលេខ ២២១ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- យោងតាមសំណើរបស់ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម

សម្រេច

ប្រការ១ .-

ត្រូវបានបំពេញបន្ថែមសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម ដូចខាងក្រោម៖

១. ឯកឧត្តម **គេត សោផាន់**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
២. លោកជំទាវ **យក់ សុខា**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិកា
៣. ឯកឧត្តម **ចៅង លីម**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤. ឯកឧត្តម **ចៅង សំអាត**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥. ឯកឧត្តម **ឃឹម សុីមុនី**	រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

៦. លោកជំទាវ **សោ ពិទ្យា**	រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	សមាជិកា
៧. ឯកឧត្តម **អ៊ុក ប្រជា**	រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	សមាជិក
៨. ឯកឧត្តម **ហោ សារុន**	រដ្ឋលេខាធិការ ក្រសួងទេសចរណ៍	សមាជិក
៩. ឯកឧត្តម **ផាន អូន**	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក ក.ប.ប នៃក្រសួងពាណិជ្ជកម្ម	សមាជិក។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ចាម រដ្ឋបាលខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២៣

តប.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

ប្រកាស
ស្តីពី
ការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម

ឧបនាយករដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលឱ្យទៅរដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៦៦ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ១._

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

ប្រការ២._

ត្រូវបានកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

ប្រការ៣._

ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ដូចដែលមានចែងក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

ប្រការ៤._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៥.-

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

នៃប្រកាសលេខ ៨៣៣ សហវ.ប្រក.អលសា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម
នៅក្រសួង ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ រដ្ឋបាលរាជធានី ខេត្ត
សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត

វិធីសាស្ត្រ	កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម		
	ទំនិញ	សំណង់	សេវាកម្ម
ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ)	ចាប់ពី ១០.០០០លានរៀល ឡើង	ចាប់ពី ១២.០០០លានរៀល ឡើង	ចាប់ពី ៨.០០០លានរៀល ឡើង
ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដ.ប.ស)	ចាប់ពី ២០០លានរៀល ដល់ក្រោម ១០.០០០លានរៀល	ចាប់ពី ២០០លានរៀល ដល់ក្រោម ១២.០០០លានរៀល	ចាប់ពី ២០០លានរៀល ដល់ក្រោម ៨.០០០លានរៀល
ការដេញថ្លៃមានកម្រិត (ដ.ក)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់
ការពិគ្រោះថ្លៃ (ព.ថ)	ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល	ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល	ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល
ការស្ទង់តម្លៃ (ស.ត)	ក្រោម ៤០លានរៀល	ក្រោម ៤០លានរៀល	ក្រោម ៤០លានរៀល
លទ្ធកម្មដោយឡែក (ល.ឡ)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់

ឧបសម្ព័ន្ធទី២

នៃប្រកាស៨៣៣ សហវ.ប្រក.អលសា ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

តារាងកម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និងសេវាកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

វិធីសាស្ត្រ	កម្រិតទឹកប្រាក់តាមប្រភេទលទ្ធកម្ម		
	ទំនិញ	សំណង់	សេវាកម្ម
ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដ.ប.អ)	ចាប់ពី ៤.០០០លានរៀល ឡើង	ចាប់ពី ៥.០០០លានរៀល ឡើង	ចាប់ពី ៣.០០០លានរៀល ឡើង
ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក (ដ.ប.ស)	ចាប់ពី ២០០លានរៀល ដល់ក្រោម ៤.០០០លានរៀល	ចាប់ពី ២០០លានរៀល ដល់ក្រោម ៥.០០០លានរៀល	ចាប់ពី ២០០លានរៀល ដល់ក្រោម ៣.០០០លានរៀល
ការដេញថ្លៃមានកម្រិត (ដ.ក)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់
ការពិគ្រោះថ្លៃ (ព.ថ)	ចាប់ពី ២០លានរៀល ដល់ក្រោម ២០០លានរៀល	ចាប់ពី ៤០លានរៀល ដល់ក្រោម ២០០លានរៀល	ចាប់ពី ២០លានរៀល ដល់ក្រោម ២០០លានរៀល
ការស្នងតម្លៃ (ស.ត)	ក្រោម ២០លានរៀល	ក្រោម ៤០លានរៀល	ក្រោម ២០លានរៀល
លទ្ធកម្មដោយឡែក (ល.ឡ)	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់	មិនមានកម្រិតទឹកប្រាក់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ : ៣០ ប្រ.ក

ប្រកាស
ស្តីពី
ការបែងចែកតួនាទីនិងភារកិច្ចរវាងសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច
- បានឃើញប្រកាសលេខ១៣៣ ប្រក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញប្រកាសលេខ២០០ ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញសារាចរណែនាំលេខ១២ សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបន្តពង្រឹងសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះ កំណត់អំពីតួនាទី ភារកិច្ចរវាងសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចក្នុងគោលបំណងបញ្ចៀសភាពស្ទួនគ្នាលើការអនុវត្តការងារដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងគុណភាពការងារនៅតាមបណ្តាអង្គភាពចំណុះក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ប្រការ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមុខងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ជំពូកទី២

មុខងារនិងភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

ផ្នែកទី១

សវនកម្មផ្ទៃក្នុង

ប្រការ៣.-

សវនកម្មផ្ទៃក្នុងនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានមុខងារជាសេនាធិការចំណុះផ្ទាល់រដ្ឋមន្ត្រី ដោយទទួលបន្ទុកអនុវត្តភារកិច្ចស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈដែលមានភារកិច្ចនិងការទទួលខុសត្រូវជារួមដូចខាងក្រោម៖

១- ពិនិត្យឡើងវិញលើមុខងារសកម្មភាពកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការយល់បរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំក្នុងការអនុវត្តឱ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធីនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព។

២- កំណត់ភាពសមស្រប គ្រប់គ្រាន់ និងផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព។

៣- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុនិងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ។

៤- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតដើម្បីធានាបានតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ញាទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការនិងរបាយការណ៍។ ក្នុងករណីអង្គភាពណាមួយអនុវត្តពុំបានសមស្របដូចបានរៀបរាប់ខាងលើ ចាំបាច់សំណូមពរអោយមានការផ្លាស់ប្តូរនិងកែលម្អ។

៥- ពិនិត្យឡើងវិញលើការគ្រប់គ្រង ថែទាំ ការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋដែលមានឱ្យត្រឹមត្រូវ។

៦- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលម្អលើការអនុវត្តកិច្ចប្រតិបត្តិការនិងផ្តល់អនុសាសន៍។

៧- ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធីនិងគម្រោងចំណាយមូលធនលើផលការងារវិជ្ជមាន ឬ អវិជ្ជមានតាមគោលបំណង គោលដៅដែលបានដាក់ចេញនិងតាមផែនការដែលបានកំណត់។

៨- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗដើម្បីធានាឱ្យ៖

- តម្រូវការអ្នកប្រើប្រាស់ ត្រូវបានកំណត់ដោយច្បាស់លាស់
- ការត្រួតពិនិត្យផ្ទៃក្នុងសមស្រប ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រ ត្រូវបានប្រព្រឹត្តទៅក្នុងដំហានសមស្រប
- ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រ ត្រូវបានធ្វើពេញលេញនិងមានភាពត្រឹមត្រូវ។

៩- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទនិងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ក្រោយពេលតម្លើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណងនិងគោលដៅដែលបានគ្រោងទុក ហើយទទួលបានលទ្ធផល មានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

១០- ពិនិត្យឡើងវិញលើនីតិវិធីនិងការអនុវត្ត ដើម្បីធានាថាវិធានការត្រូវបានដាក់ចេញក្នុងគោលបំណងការពារកេងបន្លំ។ ប្រសិនបើមានការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា។

១១- ពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពីឥរិយាបថនិងក្រមសីលធម៌ចំពោះមន្ត្រីរាជការ។

១២- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់និងកាត់បន្ថយការងារស្ទួនគ្នា។

១៣- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ហើយត្រូវធ្វើរបាយការណ៍និងសេចក្តីសន្និដ្ឋាននៃការធ្វើសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិស្តីពី៖

- សកម្មភាពកែលម្អតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង
- សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យនិងបង្កើតភាពសន្សំសំចៃ ប្រសិទ្ធភាព និងការផ្តល់លទ្ធផលល្អក្នុងកិច្ចប្រតិបត្តិការ
- សវនកម្មផ្ទៃក្នុងត្រូវធ្វើការសម្របសម្រួលការងារជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីចៀសវាងការធ្វើសវនកម្មស្ទួនគ្នា។ ករណីមានភាពមិនច្បាស់លាស់ អាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យនិងធ្វើសវនកម្មសារឡើងវិញ
- ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្រប ច្បាស់លាស់ គ្រប់គ្រាន់
- ការរាំងលើព័ត៌មាននិងបញ្ជី។

១៤- ផែនការយុទ្ធសាស្ត្រនិងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ត្រូវដាក់ជូនរដ្ឋមន្ត្រីដើម្បីពិនិត្យ សម្រេច។

១៥- វាយតម្លៃផែនការ ឬ សកម្មភាពកែលម្អលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង។ ប្រសិនបើសកម្មភាពកែលម្អនេះមិនមានលក្ខណៈសមស្របទេនោះ ត្រូវលើកយកមកពិភាក្សាបន្តដើម្បីឱ្យសម្រេចបានតាមសំណូមពរដែលអាចទទួលយកបាន។

១៦- ផ្តល់លទ្ធភាពសមស្រប គ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលម្អលើអនុសាសន៍។

១៧- ប្រធានសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនរដ្ឋមន្ត្រី។

១៨- ធ្វើរបាយការណ៍និងសេចក្តីសន្និដ្ឋាននៃសវនកម្ម ផ្ញើជូនអង្គភាពនីមួយៗក្រោមឱវាទក្រសួងដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរបាយការណ៍និងសេចក្តីសន្និដ្ឋានជូនរដ្ឋមន្ត្រី។

១៩- អនុវត្តការងារនិងភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

ផ្នែកទី២

អធិការកិច្ចរបស់ក្រសួង

ប្រការ៤.-

អធិការដ្ឋានរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាអង្គភាពស្ថិតនៅក្រោមការដឹកនាំនិងគ្រប់គ្រងរបស់ក្រសួង ដោយមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

១- ធ្វើអធិការកិច្ចក្នុងដែនសមត្ថកិច្ចក្រសួងវប្បធម៌និងវិចិត្រសិល្បៈដើម្បីប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តិជាធរមាន។

២- ធ្វើអធិការកិច្ចដោយផ្អែកលើអភិក្រម ហានិភ័យ និងករណីសង្ស័យ។

៣- ទទួលនិងធ្វើអធិការកិច្ចតាមពាក្យបណ្តឹងតវ៉ានិងបណ្តឹងបរិហាររបស់មន្ត្រីរាជការ ប្រជាពលរដ្ឋ សង្គមស៊ីវិល រួមទាំងពិនិត្យបាតុភាពអសកម្មផ្សេងៗតាមរយៈប្រព័ន្ធព័ត៌មាន ដើម្បីស្នើសុំគោលការណ៍អង្កេតស្រាវជ្រាវ ឬ/និង ដើម្បីបញ្ជូនទៅស្ថាប័នមានសមត្ថកិច្ច។

៤- អង្កេតស្រាវជ្រាវបណ្តឹងតវ៉ា បណ្តឹងបរិហារដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួង។

៥- អង្កេតស្រាវជ្រាវឡើងវិញនូវលទ្ធផលដោះស្រាយបណ្តឹងរបស់ថ្នាក់ក្រោម ដែលមានការតវ៉ាថាមិនត្រឹមត្រូវ។

៦- លើកសំណើចាត់វិធានការលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលអនុវត្តខុសតួនាទី គោលការណ៍ណែនាំ ឬរំលោភអំណាចធ្វើឱ្យប៉ះពាល់ដល់នយោបាយ សេដ្ឋកិច្ច ឬ ថវិកាជាតិ ដើម្បីសុំថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច។

៧- តាមដានការដោះស្រាយបណ្តឹង និងតឿនទារលទ្ធផលនៃការដោះស្រាយបណ្តឹងដែលបានបញ្ជូនទៅសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយ។

៨- ដើម្បីបំពេញសមត្ថកិច្ចរបស់ខ្លួន អធិការដ្ឋានមានសិទ្ធិអំណាច៖

- អញ្ជើញជនដែលពាក់ព័ន្ធមកសាកសួរនិងបំភ្លឺ
- តម្រូវឱ្យមន្ត្រីរាជការផ្តល់នូវគ្រប់ព័ត៌មាន លិខិតស្នាម របាយការណ៍ និងឯកសារតម្កល់ទុកផ្សេងៗទៀតដែលចាំបាច់
- តម្រូវឱ្យប្រធានអង្គភាពចូលរួមចំណែកធ្វើអធិការកិច្ចបច្ចេកទេសលើអង្គភាពដែលស្ថិតនៅក្រោមការដឹកនាំរបស់ខ្លួន។

៩- រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំជូនថ្នាក់ដឹកនាំពិនិត្យនិងសម្រេច។

១០- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងអំពីលទ្ធផលដែលបានធ្វើអធិការកិច្ច និងលទ្ធផលផ្សេងៗទៀតដែលអធិការដ្ឋានបានទទួលមុខការ។

១១- ធ្វើរបាយការណ៍អធិការកិច្ចអំពីលទ្ធផលការងារជូនថ្នាក់ដឹកនាំក្រសួង និងចម្លងជូនទៅក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

១២- គ្រប់របាយការណ៍នៃការធ្វើអធិការកិច្ច ឬ ការអង្កេតស្រាវជ្រាវ ត្រូវរក្សាការសម្ងាត់ដាច់ខាត។

១៣- បំពេញភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

ប្រការ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អគ្គនាយក ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អធិការនៃអធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២៣

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ ៥៣ ប្រ.ក

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះអាជ្ញាធរជាតិសំបូរព្រៃគុក

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់មេណឌីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៨៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៥ និងមាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៦ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការកំណត់មេណឌីយដ្ឋានប្រាសាទសំបូរព្រៃគុក
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៥ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិសំបូរព្រៃគុកជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌

- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹតលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៧២ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិសំបូរព្រៃគុក
- យោងតាមការចាំបាច់របស់អាជ្ញាធរជាតិសំបូរព្រៃគុក។

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះ មានគោលបំណងកំណត់អំពីតួនាទីនិងភារកិច្ចរបស់ការិយាល័យនិងអង្គភាពចំណុះអាជ្ញាធរជាតិសំបូរព្រៃគុក ដែលហៅកាត់ថា អ.ជ.ស.ព.។

ជំពូកទី២

នាយកដ្ឋានក្រោមចំណុះអាជ្ញាធរជាតិសំបូរព្រៃគុក

ប្រការ២.-

អាជ្ញាធរជាតិសំបូរព្រៃគុក មាននាយកដ្ឋានក្រោមចំណុះចំនួន៦ដូចខាងក្រោម៖

១. នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

២. នាយកដ្ឋានសណ្តាប់ធ្នាប់

៣. នាយកដ្ឋានបុរាណវិទ្យានិងអភិរក្ស

៤. នាយកដ្ឋានរៀបចំដែនដី លំនៅដ្ឋាន និងប្រជាសាស្ត្រ

៥. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

៦. នាយកដ្ឋានបរិស្ថាន។

ជំពូកទី៣

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

ប្រការ៣.-

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យរដ្ឋបាលនិងព័ត៌មានវិទ្យា

២. ការិយាល័យផែនការនិងគណនេយ្យ

៣. ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល។

ប្រការ៤.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យរដ្ឋបាលនិងព័ត៌មានវិទ្យា

- គ្រប់គ្រងចរន្តលិខិតចេញ-ចូល និងឯកសារផ្សេងៗ

- រៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល និងរៀបចំសំណុំលិខិតផ្សេងៗ
- គ្រប់គ្រង ជួសជុល ថែទាំ និងធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ អ.ជ.ស.ព.
- គ្រប់គ្រងនិងសម្របសម្រួលផ្តល់សេវារដ្ឋបាលនានាដែលនៅក្រោមសមត្ថកិច្ចរបស់ អ.ជ.ស.ព.
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គទូត អង្គការជាតិ អង្គការអន្តរជាតិ និងសមាគមនានា ដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀងនិងគម្រោងស្នើសុំជំនួយពាក់ព័ន្ធនឹង អ.ជ.ស.ព.
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសនិងវិទ្យាសាស្ត្រជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ
- រៀបចំផែនការផ្សព្វផ្សាយអំពីរមណីយដ្ឋានប្រាសាទសំបូរព្រៃគុកនិងទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគក្នុងតំបន់រណប
- រៀបចំផ្សព្វផ្សាយសេចក្តីសម្រេច សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតក្នុងគេហទំព័ររបស់ អ.ជ.ស.ព.
- ផលិតវីដេអូ ថតរូបភាពពាក់ព័ន្ធនឹងសកម្មភាពរបស់ អ.ជ.ស.ព.
- រៀបចំរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំរបស់ អ.ជ.ស.ព.
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យផែនការនិងគណនេយ្យ

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ ផែនការអភិវឌ្ឍ និងគម្រោងវិនិយោគរបស់ អ.ជ.ស.ព.
- រៀបចំផែនការយុទ្ធសាស្ត្រថវិកានិងគម្រោងថវិកាប្រចាំឆ្នាំ
- កាន់កាប់ គ្រប់គ្រងបញ្ជីការគណនេយ្យ គ្រប់គ្រងចំណូលនិងទូទាត់ចំណាយរបស់ អ.ជ.ស.ព.
- គ្រប់គ្រង ចាត់ចែង និងតាមដានការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មរបស់អាជ្ញាធរជាតិសំបូរព្រៃគុកប្រចាំត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ ដើម្បីសុំការពិនិត្យសម្រេចពីប្រធានក្រុមប្រឹក្សាភិបាល បញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលគម្រោងចំណូល ចំណាយថវិកា និងរំលឹកអំពីកិច្ចប្រតិបត្តិការរបស់នាយកដ្ឋានចំណុះ អ.ជ.ស.ព.
- រៀបចំកម្មវិធីចំណាយប្រចាំឆ្នាំនិងប្រចាំត្រីមាស
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល

- រៀបចំបែបបទដំឡើងឋានន្តរស័ក្តិ ដំឡើងថ្នាក់ និងលើកសរសើរជូនមន្ត្រីរាជការ
- គ្រប់គ្រងបៀវត្ស ក្របខ័ណ្ឌ និងបញ្ជីវត្តមានរបស់មន្ត្រីនិងបុគ្គលិក
- រៀបចំផែនការស្រាវជ្រាវនិងបណ្តុះបណ្តាលរបស់ អ.ជ.ស.ព. សម្រាប់រយៈពេលខ្លី មធ្យម និងវែងពាក់ព័ន្ធជាមួយដៃគូជាតិនិងអន្តរជាតិ
- សហការជាមួយនាយកដ្ឋានជំនាញរៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលាលើការងារអភិរក្សបេតិកភណ្ឌវប្បធម៌ ធម្មជាតិ និងធនធានមនុស្ស
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៤
នាយកដ្ឋានសណ្តាប់ធ្នាប់

ប្រការ៥.-

នាយកដ្ឋានសណ្តាប់ធ្នាប់ មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យនីតិវិធី

២. ការិយាល័យសណ្តាប់ធ្នាប់

៣. ការិយាល័យអន្តរាគមន៍។

ប្រការ៦.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យនីតិវិធី

- សម្របសម្រួលការងាររដ្ឋបាលនិងរៀបចំផែនការសកម្មភាពរបស់នាយកដ្ឋាន
- ចាត់វិធានការ សហការ អង្កេតស្រាវជ្រាវសកម្មភាពដែលបង្កមហន្តរាយដល់សម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិក្នុងដែនការពាររបស់ អ.ជ.ស.ព.
- រៀបចំឯកសារនិងបំពេញបែបបទផ្សេងៗដែលពាក់ព័ន្ធនឹងបទល្មើសក្នុងរមណីយដ្ឋាន
- សហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីមានវិធានការទប់ស្កាត់ចំពោះរាល់សកម្មភាពទាំងឡាយណាដែលបង្កផលប៉ះពាល់ដល់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យសណ្តាប់ធ្នាប់

- លើកផែនការ ចាត់ចែងកងកម្លាំងការពារនៅតាមគោលដៅនានាដែលបានកំណត់
- ការពារនិងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងរមណីយដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យអន្តរាគមន៍

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនិងអង្គភាពពាក់ព័ន្ធ ដើម្បីអន្តរាគមន៍បន្ទាន់នៅពេលមានបទល្មើសណាមួយកើតឡើងក្នុងតំបន់ការពារ
- អង្កេតតាមដាននិងទប់ស្កាត់សកម្មភាពល្មើសផ្សេងៗនៅក្នុងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីការពារគោលដៅ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៥
នាយកដ្ឋានបុរាណវិទ្យានិងអភិរក្ស

ប្រការ៧.-

នាយកដ្ឋានបុរាណវិទ្យានិងអភិរក្ស មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យរមណីយដ្ឋាន

២. ការិយាល័យបុរាណវិទ្យានិងស្រាវជ្រាវ

៣. ការិយាល័យអភិរក្ស។

ប្រការ៨.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យរមណីយដ្ឋាន

- រៀបចំផែនការមេស្តីពីការគ្រប់គ្រងនិងថែទាំប្រាសាទនិងរចនាសម្ព័ន្ធបុរាណក្នុងរមណីយដ្ឋាន
- រៀបចំទិសដៅ សិក្សា ស្រាវជ្រាវ និងពិសោធន៍ក្នុងគោលបំណងអភិរក្សនិងអប់រំផ្នែកបុរាណវិទ្យា
- ធ្វើបញ្ជីសារពើភណ្ឌ ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យនៃតម្លៃបេតិកភណ្ឌក្នុងរមណីយដ្ឋាន
- រៀបចំគម្រោងវិក្រឹតការបណ្តុះបណ្តាលបុគ្គលិកបច្ចេកទេសលើការអភិរក្សបុរាណវិទ្យា
- រៀបចំនិងផ្សព្វផ្សាយអំពីតម្លៃបេតិកភណ្ឌនៃរមណីយដ្ឋានដល់សាធារណជន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យបុរាណវិទ្យានិងស្រាវជ្រាវ

- រៀបចំផែនការគ្រប់គ្រង ស្រាវជ្រាវ ចងក្រងបេតិកភណ្ឌវប្បធម៌ក្នុងរមណីយដ្ឋាន
- ធ្វើការអង្កេត វាស់ស្ទង់ និងធ្វើកំណាយបុរាណវិទ្យាក្នុងរមណីយដ្ឋាន ព្រមទាំងចាត់វិធានការបង្ការ ឬ សង្គ្រោះស្ថានីយបុរាណតាមការចាំបាច់
- ត្រួតពិនិត្យនិងសម្របសម្រួលលើការស្រាវជ្រាវក្នុងរមណីយដ្ឋានសម្រាប់ស្ថាប័នជាតិនិងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យអភិរក្ស

- រៀបចំបញ្ជីស្តីពីស្ថានភាពប្រាសាទនិងផែនទីចង្អុលហានិភ័យសម្រាប់អភិរក្សក្នុងរមណីយដ្ឋាន
- រៀបចំកម្មវិធីនិងអនុវត្តការងារអភិរក្ស វត្ថុបុរាណ ប្រាសាទ និងស្ថានីយបុរាណ
- រៀបចំនិងគ្រប់គ្រងពិព័រណ៍ មន្ទីរពិសោធន៍ និងវត្ថុបុរាណនៅអភិរក្សដ្ឋានប្រាសាទសំបូរព្រៃគុក
- ត្រួតពិនិត្យនិងសម្របសម្រួលលើការអភិរក្សក្នុងរមណីយដ្ឋានសម្រាប់ស្ថាប័នជាតិនិងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៦

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ

ប្រការ៩.-

នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យរៀបចំដែនដី

២. ការិយាល័យលំនៅឋាន

៣. ការិយាល័យប្រជាសាស្ត្រ។

ប្រការ១០.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យរៀបចំដែនដី

- សិក្សាស្រាវជ្រាវនិងប្រមូលព័ត៌មានអំពីការប្រើប្រាស់ដីធ្លី ដើម្បីរៀបចំផែនការមេសម្រាប់ការអភិរក្ស និងអភិវឌ្ឍដីធ្លីក្នុងតំបន់ការពារ
- សហការជាមួយអាជ្ញាធរមូលដ្ឋាននិងអាជ្ញាធរពាក់ព័ន្ធលើការចុះបញ្ជីដីធ្លី ដោយអនុលោមតាមគោលនយោបាយជាតិនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើការវិភាគនិងវាយតម្លៃអំពីផលប៉ះពាល់បណ្ដាលមកពីគម្រោងវិនិយោគនិងអភិវឌ្ឍ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងសុំការពិនិត្យសម្រេចពីក្រុមប្រឹក្សាភិបាល
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋានដើម្បីជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យលំនៅឋាន

- គ្រប់គ្រងទិន្នន័យបច្ចេកទេសនិងលិខិតរដ្ឋបាលនៃការស្នើសុំនានា
- ទទួល ចុះត្រួតពិនិត្យទីតាំង ធ្វើរបាយការណ៍ និងព្រាងលិខិតឆ្លើយតបតាមពាក្យស្នើសុំរបស់ប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋានដើម្បីសុំការពិនិត្យ សម្រេច
- តាមដានការអនុវត្តការសាងសង់សំណង់នានានិងធ្វើរបាយការណ៍អំពីលទ្ធផលជូនថ្នាក់ដឹកនាំដើម្បីពិនិត្យ សម្រេច
- ផ្សព្វផ្សាយពីគោលការណ៍គ្រប់គ្រងសំណង់និងគំរូផ្ទះខ្មែរដល់ប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋានក្នុងតំបន់ការពាររមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- ចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងតំបន់ការពាររមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យប្រជាសាស្ត្រ

- សិក្សាស្រាវជ្រាវពីការវិវត្តប្រជាសាស្ត្រនិងភូមិសាស្ត្រនៃភូមិនីមួយៗ
- ចូលរួមរៀបចំផែនការអភិវឌ្ឍសហគមន៍និងតាមដានពីការវិវត្តកម្រិតជីវភាពរបស់ប្រជាជន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៧
នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

ប្រការ១១.-

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យគ្រប់គ្រងទេសចរណ៍

២. ការិយាល័យសេវាកម្មនិងសំណង់ទេសចរណ៍

៣. ការិយាល័យផ្សព្វផ្សាយទេសចរណ៍។

ប្រការ១២.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យគ្រប់គ្រងទេសចរណ៍

- កំណត់ទិសដៅនិងលើកផែនការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់រមណីយដ្ឋាន ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធស្របតាមគោលនយោបាយជាតិស្តីពីវិស័យទេសចរណ៍របស់រាជរដ្ឋាភិបាល
- សម្រង់ស្ថិតិភ្ញៀវទេសចរដែលមកទស្សនានៅរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក
- សិក្សាដើម្បីធ្វើផែនការមេវិស័យទេសចរណ៍ក្នុងរមណីយដ្ឋាន
- សហការសម្របសម្រួលលើការងារមគ្គុទ្ទេសក៍សហគមន៍
- ត្រួតពិនិត្យរាល់ការថតរូបភាព ភាពយន្ត និងវីដេអូក្នុងរមណីយដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យសេវាកម្មនិងសំណង់ទេសចរណ៍

- គ្រប់គ្រងនិងត្រួតពិនិត្យរាល់សំណង់និងសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋាន
- សិក្សានិងបង្កើនការស្វែងរកទីផ្សារលក់ផលិតផលវប្បធម៌របស់សហគមន៍
- គ្រប់គ្រងពិធីនានាដែលរៀបចំនៅក្នុងរមណីយដ្ឋានសំបូរព្រៃគុក
- សហការជាមួយស្ថាប័នពាក់ព័ន្ធនានាដើម្បីរៀបចំហេដ្ឋារចនាសម្ព័នទេសចរណ៍ក្នុងតំបន់
- រៀបចំខ្សែទស្សនាចរណ៍ក្នុងរមណីយដ្ឋាន
- រៀបចំនិងត្រួតពិនិត្យជាប្រចាំនូវគុណភាពសេវាកម្មទេសចរណ៍នានាក្នុងរមណីយដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យផ្សព្វផ្សាយទេសចរណ៍

- ត្រួតពិនិត្យរាល់ការដាក់ស្លាក ឬ ផ្ទាំងប៉ាណូផ្សព្វផ្សាយនានាក្នុងរមណីយដ្ឋាន
- ផ្សព្វផ្សាយអំពីគោលដៅទស្សនាថ្មីៗនៅក្នុងរមណីយដ្ឋាន
- តាក់តែងនិងផ្សព្វផ្សាយរាល់ឯកសារនានាពាក់ព័ន្ធទេសចរណ៍ក្នុងរមណីយដ្ឋាន
- ជំរុញការទំនាក់ទំនងជាមួយប្រតិបត្តិករទេសចរណ៍ជាតិ អន្តរជាតិ
- បំផុសគំនិតឱ្យសហគមន៍បង្កើនផលិតផលក្នុងតំបន់សម្រាប់ភ្ញៀវទេសចរ
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៨
នាយកដ្ឋានបរិស្ថាន

ប្រការ១៣.-

នាយកដ្ឋានបរិស្ថាន មានការិយាល័យចំណុះចំនួន៣៖

១. ការិយាល័យទេសភាពវប្បធម៌

២. ការិយាល័យធនធានធម្មជាតិ

៣. ការិយាល័យគាំពារបរិស្ថាន។

ប្រការ១៤.-

តួនាទីភារកិច្ចរបស់ការិយាល័យនីមួយៗ មានដូចតទៅ៖

១. ការិយាល័យទេសភាពវប្បធម៌

- រៀបចំផែនការសកម្មភាពគ្រប់គ្រងទេសភាពវប្បធម៌
- សិក្សាស្រាវជ្រាវទេសភាពវប្បធម៌ បណ្តុះកូនឈើ ដាំដើមឈើ ដើម្បីលើកតម្លៃទេសភាពវប្បធម៌ដែលមានទំនាក់ទំនងនឹងប្រពៃណីខ្មែរ
- សហការទប់ស្កាត់គ្រប់សកម្មភាពដែលបង្កផលប៉ះពាល់ដល់ទេសភាពវប្បធម៌ក្នុងរមណីយដ្ឋាន
- ផ្សព្វផ្សាយ អប់រំដល់សាធារណជនដើម្បីលើកកម្ពស់ការចូលអភិរក្សនិងអភិវឌ្ឍទេសភាពវប្បធម៌
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានាក្នុងការអភិរក្សនិងអភិវឌ្ឍទេសភាពវប្បធម៌
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

២. ការិយាល័យធនធានធម្មជាតិ

- រៀបចំផែនការនិងសកម្មភាពគ្រប់គ្រងធនធានធម្មជាតិ
- សិក្សាស្រាវជ្រាវអំពីរុក្ខជាតិ ថែទាំព្រៃឈើធម្មជាតិ សត្វព្រៃ និងសហការទប់ស្កាត់បទល្មើសបំផ្លាញព្រៃឈើនិងសត្វព្រៃគ្រប់រូបភាព
- ផ្សព្វផ្សាយនិងអប់រំដល់សាធារណជនអំពីអត្ថប្រយោជន៍ព្រៃឈើនិងសត្វព្រៃក្នុងរមណីយដ្ឋាន
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានាក្នុងការជំរុញការអនុវត្តកម្មវិធីអភិរក្សព្រៃឈើ និងសត្វព្រៃក្នុងតំបន់រមណីយដ្ឋាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

៣. ការិយាល័យគាំពារបរិស្ថាន

- រៀបចំផែនការនិងសកម្មភាពគ្រប់គ្រងគាំពារបរិស្ថាន
- គ្រប់គ្រងសំណល់រឹងនិងរៀបចំសួន ដើម្បីលើកកម្ពស់សោភ័ណភាពរមណីយដ្ឋាន
- គ្រប់គ្រងទឹកនៅក្នុងរមណីយដ្ឋាននិងការសាយភាយជាតិពុលក្នុងទឹក
- សិក្សានិងតាមដានព័ត៌មានទាក់ទងនឹងបម្រែបម្រួលអាកាសធាតុនៅក្នុងរមណីយដ្ឋាន
- ផ្សព្វផ្សាយនិងអប់រំសាធារណជនឱ្យយល់ដឹងអំពីផលប៉ះពាល់បរិស្ថានរមណីយដ្ឋាន
- សហការជាមួយអង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍នានាក្នុងការជំរុញអនុវត្តកម្មវិធីថែទាំបរិស្ថាន
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ
- ទទួលបន្ទុកភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ជំពូកទី៩
អង្គភាពលទ្ធកម្ម

ប្រការ១៥.-

អង្គភាពលទ្ធកម្ម មានរចនាសម្ព័ន្ធស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីអគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុកនិងជាលេខាធិការដ្ឋានឱ្យគណៈកម្មាធិការលទ្ធកម្ម។

ប្រការ១៦.-

អង្គភាពលទ្ធកម្មទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹតលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី១០
អង្គភាពសវនកម្មផ្ទៃក្នុង

ប្រការ១៧.-

អង្គភាពសវនកម្មផ្ទៃក្នុងរបស់អាជ្ញាធរជាតិសំបូរព្រៃគុក ត្រូវទទួលខុសត្រូវអនុវត្តមុខងារឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារនិងវាយតម្លៃសកម្មភាពរបស់អង្គភាព ដើម្បីជាជំនួយសម្រាប់ថ្នាក់ដឹកនាំនិងក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិសំបូរព្រៃគុក។

ប្រការ១៨.-

អង្គភាពសវនកម្មផ្ទៃក្នុងទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងទៅតាមបណ្ដាក្រសួងស្ថាប័ននិងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ជំពូកទី១១
អវសានប្បញ្ញត្តិ

ប្រការ១៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ២០.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អគ្គនាយកអាជ្ញាធរជាតិសំបូរព្រៃគុក ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិនា ឆ្នាំ២០២៣

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

កន្លែងទទួល៖

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ៥៣ ប្រក. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣

អង្គការលេខរបស់នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ



ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៣ ប្រក. ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

អង្គការលេខរបស់នាយកដ្ឋានសណ្ដាប់ធ្នាប់



ឧបសម្ព័ន្ធនៃប្រកាសលេខ ៥៣ ប្រក. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣

អង្គការលេខរបស់នាយកដ្ឋានបុរាណវិទ្យានិងអភិរក្ស



ឧបសម្ព័ន្ធនៃប្រកាសលេខ ៥៣ ប្រក. ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣
អង្គការលេខរបស់នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ



ឧបសម្ព័ន្ធនៃប្រកាសលេខ ៥៣ ប្រក. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣

អង្គការលេខរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍



ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៣ ប្រក. ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២៣

អង្គការលេខរបស់នាយកដ្ឋានបរិស្ថាន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៤៣១ រ៉ែ.អប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ

លេខ ០៤៣១ រ៉ែ.អប្រក.លអ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឌស្ទ័នឥន្ធនៈ និងស្ថានីយ៍រួមប្រេងនិង

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាព សម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ របស់លោកស្រី **លាន ផៀម**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា លាន ផៀម** ស្ថិតនៅភូមិថ្លក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ របស់លោកស្រី **លាន ផៀម** (**ម្ចាស់ស្ថានីយ**)។

ប្រការ២.-

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
២. មិនត្រូវបំពាក់វ៉ានបិទ បើកនៅជាប់នឹងតួបំពង់ខ្យល់ប្រេងឥន្ធនៈ
៣. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៤. ត្រូវមានរបាំងការពារបំពង់ខ្យល់ប្រេងឥន្ធនៈពីការប៉ះទង្គិច
៥. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
៦. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើស ពី ៦ម៉ែត្រ

៧. ត្រូវមានគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
៨. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
៩. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១០. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក
១១. ត្រូវសង់របងជញ្ជាំងធ្វើពីវត្ថុធាតុមិនឆាបឆេះ និងកំពស់អប្បបរមា ៣ម៉ែត្រ បាំងជិតនៅព្រំដីស្ថានីយដែលនៅជាប់នឹងព្រំដីលំនៅដ្ឋាន។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០៤៣១ រ៉ែ.អប.ក.លអ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២២ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៤៣១..រ.ម.ក:អាជ្ញ.ចអ ចុះថ្ងៃទី.....២៤.......ខែ...មិថុនា........ឆ្នាំ២០២២ នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តបន្ទាយមានជ័យ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ...១០.កើត.ខែ..ជេស្ឋ...ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.២៤..ខែ...មិថុនា.ឆ្នាំ២០២២

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

ស៊ុយ_សែម

<u>កន្លែងទទួល</u>:

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រដ្ឋបាលខេត្តបន្ទាយមានជ័យ

-ដូចប្រការ១៣

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី